ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីជូនដំណឹង

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់សាធារណៈជន ជាពិសេសបងប្អូនកម្មករនិយោជិត មេត្តាជ្រាបថា ដោយក្តាប់ជាប់នូវស្ថានភាពជាក់ស្តែង តម្រូវការចាំបាច់ និងកង្វល់របស់បងប្អូនកម្មករនិយោជិត ដែលរោងចក្របិទទ្វារដោយម្ចាស់រត់ចោលនោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានសម្រេចផ្តល់បុរេប្រទានថវិកាសម្រាប់ទូទាត់ប្រាក់ឈ្នួល និងប្រាក់អត្ថប្រយោជន៍ជូនកម្មករនិយោជិតនៅរោងចក្រចំនួន៩ រួមមាន ១. រាជធានីភ្នំពេញ ចំនួន ៥រោងចក្រ ២. ខេត្តកណ្តាល ចំនួន ១រោងចក្រ ៣. ខេត្តកំពង់ស្ពឺ ចំនួន ៣រោងចក្រ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈសូមជូនដំណឹងដល់បងប្អូនអតីតកម្មករនិយោជិត នៅ **រោងចក្រអេវើរ៉ាយថិចស្តាយ** នៅភូមិរំដួល ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ សូមមេត្តាពិនិត្យបញ្ជី និងបើកប្រាក់ឈ្នួល និងប្រាក់អត្ថប្រយោជន៍ជូនកម្មករនិយោជិត ហើយបើកប្រាក់ដោយផ្ទាល់ដល់សាមីខ្លួន **នៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ស្ពឺ ចាប់ពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ រហូតដល់ ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ រៀងរាល់ម៉ោងធ្វើការ។**

**កម្មករនិយោជិតត្រូវយកមកជាមួយនូវឯកសារដូចខាងក្រោម៖**

១. កាតសម្គាល់ខ្លួនកម្មករនិយោជិតក្នុងរោងចក្រ (ច្បាប់ដើម) ឬសៀវភៅការងារ ឬបណ្ណបេឡាជាតិរបបសន្តិសុខសង្គម ឬអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន ឬកិច្ចសន្យាការងារ។

២. បណ្ណបើកប្រាក់ឈ្នួលប្រចាំខែរបស់កម្មករនិយោជិតម្នាក់ៗ (បើមាន)។

អាស្រ័យហេតុនេះសូមសាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតមេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃព្រហស្បតិ៍ ២រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨

ទូរស័ព្ទទំនាក់ទំនង៖ ០៧៧ ៩៨៨ ៧៩៩

០៧៧ ៤៧៤ ១៦៨